**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :..................៣៤៦..........ក.ប/ស.ជ.៣

# សេចក្តីជូនដំណឹង
## ស្តីពី
## ក្រុមហ៊ុន "ខ្មែរជួយខ្មែរ" ដែលបានធ្វើការបោកប្រាស់យកលុយពីប្រជាពលរដ្ឋ ក្រោមរូបភាពបញ្ជូនទៅធ្វើការនៅបរទេស

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនដំណឹងដល់សាធារណៈជន ឱ្យបានជ្រាបថា នាពេលថ្មីៗនេះ មានក្រុមហ៊ុនមួយឈ្មោះថា "ខ្មែរជួយខ្មែរ" ដែលមានអាសយដ្ឋានចល័តមិនច្បាស់លាស់ បានធ្វើការបោកប្រាស់យកលុយពីប្រជាពលរដ្ឋជាច្រើននាក់ដែលរស់នៅតាមបណ្តាខេត្តនានា ក្រោមរូបភាពជាក្រុមហ៊ុនមួយដែលធ្វើការបញ្ជូនប្រជាពលរដ្ឋខ្មែរទៅធ្វើការ និងរស់នៅក្នុងប្រទេសអូស្ត្រាលីដោយស្របច្បាប់ ដោយតម្រូវឱ្យពួកគាត់បង់ប្រាក់ចំនួន ២៥០០ដុល្លារ ក្នុងម្នាក់។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈសូមធ្វើការបញ្ជាក់ថា ក្រុមហ៊ុន"ខ្មែរជួយខ្មែរ" គឺពុំមានអាជ្ញាប័ណ្ណអនុញ្ញាតឱ្យធ្វើការបញ្ជូនប្រជាពលរដ្ឋខ្មែរទៅធ្វើការនៅបរទេសឡើយ។

ជាមួយគ្នានេះដែរ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមធ្វើការក្រើនរំលឹកដល់បងប្អូនប្រជាពលរដ្ឋខ្មែរគ្រប់រូបនៅទូទាំងប្រទេស ដែលមានបំណងទៅធ្វើការនៅបរទេស សូមមានការប្រុងប្រយ័ត្នខ្ពស់មុនពេលជឿជាក់ សម្រេចចិត្តផ្តល់សេចក្តីទុកចិត្តទៅលើក្រុមហ៊ុនណាមួយ។ ដើម្បីទទួលបានព័ត៌មានបន្ថែមច្បាស់លាស់ស្តីពីក្រុមហ៊ុនស្របច្បាប់ដែលទទួលបានអាជ្ញាប័ណ្ណពីក្រសួង សូមបងប្អូនប្រជាពលរដ្ឋអាចធ្វើការទំនាក់ទំនងមកនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម តាមរយៈទូរស័ព្ទលេខ 023 880 474 នៅរៀងរាល់ម៉ោងធ្វើការ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា បងប្អូនប្រជាពលរដ្ឋនឹងខិតខំយកចិត្តទុកដាក់អនុវត្តចំពោះសេចក្តីជូនដំណឹងនេះ និងធ្វើទេសន្តរប្រវេសន៍ទៅធ្វើការនៅបរទេសដោយស្មារតីប្រុងប្រយ័ត្នខ្ពស់៕

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន៖**

- ក្រសួងមហាផ្ទៃ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- សមាគមទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា
- សមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា
  (ដើម្បីជូនជ្រាប)
- ឯកសារ កាលប្បវត្តិ